# ការសម្ភាសន៍របស់ម៉ា ឆើម គង់

កៈ អ្នកសម្ភាសន៍គេមាន រត្ន ពិសី ខៈ អ្នកដែរគេត្រូវសម្ភាសន៍មានឈ្មោះ ឆើម គង់

**<u>ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ម៉ា ឆើម គង់</u>**

ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ម៉ា ឆើម គង់ហើយគាត់បានធ្លាប់ឆ្លងកាត់នៅរឿងរ៉ាវជាច្រើននៅក្នុងជីវិតរបស់គាត់ហើយមានការលំបាកជាច្រើននៅក្នុងជីវិតរបស់គាត់តែគាត់បានជំនះគ្រាប់ឧបសគ្គហើយនិងគ្រាប់បញ្ហាបែបយ៉ាងនៅចំពោះមុខរបស់គាត់ហើយគាត់ជាអ្នកធ្វើថ្នាំលក់ទាំងពីអ្នកប្តីប្រពន្ធរបស់គាត់ទោះម៉ាគាត់មានវ័យច្រើនមកហើយគាត់នៅតែមានការតស៊ូទៅបេះស្លឹកថ្នាំមកធ្វើលក់នៅឯផ្សារទៀតគាត់ជាបុគ្គលមួយដែរមានការលំបាកខ្លាំងនៅក្នុងជីវិតរបស់គាត់ហើយគាត់ជាមនុស្សម្នាក់ដែរមានការបារម្ភច្រើននៅគ្រាប់បញ្ហាហើយនិងជាមួយអ្នកដ៏ទៃ។ហើយម៉ាគាត់រៀងកាចបន្តិចតែគាត់មានចិត្តល្អហើយចេះយកអាសារអ្នកដ៏ទៃហើយនិងគាត់មានការយល់ជាច្រើននៅក្នុងជីវិតគាត់។ជាពិសេសគាត់នៅចាំទាំងអស់នៅរឿងរ៉ាវដែរគាត់បានឆ្លងកាត់ពីមួយជំនាន់ទៅមួយជំនាន់។

ធ្វើឡើងនៅភូមិខ្ពប ឃុំកោះឧកញ៉ាតី ស្រុកខ្សាច់កណ្តាល កណ្តាល ធ្វើឡើងនៅថ្ងៃទី ១៦ ខែ ០៥ ឆ្នាំ ២០១៨។

កៈ ជាដំបូងខ្ញុំសូមជំរាប់សួរម៉ាហើយខ្ញុំបាទមានឈ្មោះថា រត្ន ពិសីហើយខ្ញុំសូមអនុញ្ញាតម៉ាដោយសូមធ្វើការសម្ភាសន៍ពីជីវប្រវត្តិរបស់ម៉ាហើយខ្ញុំធ្វើឡើងដោយសាកលវិទ្យាល័យមួយដែរមានឈ្មោះថា សាកលវិទ្យាល័យ BYU ហើយខ្ញុំធ្វើនិងដើម្បីថៃរក្សាជីវប្រវត្តិរបស់ម៉ាហើយនិងថៃរក្សាជីវប្រវត្តិរបស់ជីដូនជីតារបស់ម៉ាដើម្បីទុកឲ្យកូនចៅជំនាន់ក្រោយរបស់អ៊ុំស្រីថាអ្នកជំនាន់មុខថាមានការលំបាកហើយបានជួបឧបសគ្គអ្វីខ្លះនៅក្នុងជីវិតរបស់ម៉ាច្រើនបាទចឹងខ្ញុំធ្វើឡើងនៅថ្ងៃទី១៦ខែ០៥ឆ្នាំ២០១៨។

កៈ បាទ!ចឹងតើម៉ាមានឈ្មោះអ្វីដែលម៉ា?

ខៈ ខ្ញុំមានឈ្មោះ ឆើម គង់។

កៈ បាទ!ចឹងតើម៉ាមានឈ្មោះគេហៅខាងក្រៅទេ?

ខៈ ខ្ញុំអត់មានទេឈ្មោះខាងក្រៅនិងនោះគេហៅខ្ញុំតែឈ្មោះនិងមួយទេអត់មានឈ្មោះអីផ្សេងទេ។

កៈ
បាទ!ហើយអញ្ចឹងម៉ាមានឈ្មោះតែមួយនិងទេអត់មានឈ្មោះគេហៅខាងក្រៅទេម៉ាដូចគេឈ្មោះថាផ្សេងទេម៉ាណោះ។
ហើយអញ្ចឹងម៉ាតើសព្វថ្ងៃនិងម៉ាមានប្រជន្មប៉ុន្មានដែរសព្វថ្ងៃនិងម៉ា?

ខៈ ចាំ! សព្វថ្ងៃនិងខ្ញុំមានអាយុ៧៧ឆ្នាំ។

កៈ
បាទ!ហើយអញ្ចឹងសព្វថ្ងៃនិងម៉ាមានប្រជន្ម៧៧ឆ្នាំហើយម៉ាអញ្ចឹងម៉ាមានប្រជន្មច្រើនដែរម៉ា?

ខៈ ចាំ!សព្វថ្ងៃនិងខ្ញុំមានអាយុ៧៧ឆ្នាំហើយរាប់ទាំងឆ្នាំថ្មីនិងណា។

កៈ បាទ!ហើយអញ្ចឹងម៉ាមាននៅចាំថ្ងៃខែឆ្នាំកំណើតរបស់ម៉ាផ្ទាល់ទេម៉ា?

ខៈ ខ្ញុំអត់ចាំទេថ្ងៃខែឆ្នាំកំណើតនោះគ្មានចាំទេរាល់ថ្ងៃនិងនោះ។

កៈ បាទ!
ហើយអញ្ចឹងម៉ាអត់ចាំថាម៉ាមានថ្ងៃខែឆ្នាំកំណើតទេណាម៉ា។ហើយអញ្ចឹងម៉ាមាននៅចាំថាម៉ាមានឆ្នាំខ្មែរយើងទេម៉ា?

ខៈ ខ្ញុំអត់ចាំទេថាឆ្នាំអីទេ។

កៈ បាទ! ហើយអញ្ចឹងម៉ាមាននៅចាំថាម៉ាមានឆ្នាំដូចជា ឆ្នាំ ជូត ឆ្លូវ ខាល ថោះទេម៉ា?

ខៈ ចាំ!ខ្ញុំឆ្នាំ មមី។

កៈ
បាទ!ហើយអញ្ចឹងម៉ាមានឆ្នាំមមីណាម៉ាណោះ។ហើយអញ្ចឹងម៉ាមានចាំទីកន្លែងកំណើតរបស់ម៉ាផ្ទាល់ទេម៉ា?

ខៈ ខ្ញុំមានទីកន្លែងកំណើតនៅនឹងម៉ងនិង។

កៈ
បាទ!ហើយអញ្ចឹងម៉ាជាអ្នកស្រុកកំណើតនៅនិងម៉ា។ហើយអញ្ចឹងនៅនឹងគេហៅភូមិមានឈ្មោះអីគេដែលម៉ា?

ខៈ អរនៅនិងគេហៅឃុំកោះឧកញ៉ាតី ។

កៈ ហើយអញ្ចឹងនៅនិងគេហៅឃុំកោះឧកញ៉ាតីហើយអញ្ចឹងគេហៅភូមិអីគេដែរម៉ា?

ខៈ នៅនឹងគេហៅភូមិ ខ្ពប ឃុំកោះឧកញ៉ាតី

កៈ ស្រុកខ្សាច់កណ្ដាល
ខេត្តកណ្ដាលណាម៉ាណោះ។ហើយអញ្ចឹងតើម៉ាមានបងប្អូនបង្កើតប៉ុន្មាននាក់ដែលម៉ា?

ខៈ ចាំ! ខ្ញុំមានបងប្អូនបង្កើតខ្ញុំមាន៥នាក់។

កៈ បាទ!
ហើយអញ្ចឹងម៉ាមានបងប្អូនបង្កើតរបស់ម៉ាមាន៥នាក់។ហើយអញ្ចឹងម៉ាជាកូនទីប៉ុន្មានដែរម៉ា?

ខៈ ចាំ! ខ្ញុំជាកូនទី២។

កៈ បាទ!ហើយអញ្ចឹងម៉ាជាកូនទី២?

ខៈ ចាំ!តែបងប្អូនខ្ញុំនៅសល់តែ៣នាក់ទេគាត់ស្លាប់អស់២នាក់ហើយ។

កៈ បាទ!ហើយអញ្ចឹងម៉ាមាននៅចាំឈ្មោះបងប្អូនរបស់ម៉ាទេ?

ខៈ ឈ្មោះបងប្អូនរបស់ខ្ញុំមានឈ្មោះ ញ៉ាម ឈ្មោះ ចិន។

កៈ បាទ!ហើយអញ្ចឹងម៉ាមានចាំឈ្មោះបងគេបង្អស់របស់ម៉ាមានឈ្មោះអ្វីដែរម៉ា?

ខៈ ឈ្មោះបងខ្ញុំបង្អស់និងមានឈ្មោះពេជ្យ
គាត់ស្លាប់ហើយកាលពីជំនាន់ប៉ុលពតមកម្លេះហើយបន្ទាប់មកខ្ញុំ។

កៈ បាទ!ចឹងបងប្អូនរបស់ម៉ាតើមានស្រីប៉ុន្មានប្រុសប៉ុន្មានដែលម៉ា?

ខៈ ស្រី២ប្រុស៣នាក់សំរាប់បងប្អូនបង្កើតរបស់ខ្ញុំនឹង។

កៈ បាទ!ស្រី២ប្រុស៣ចឹង៥នាក់បាទចឹងរបស់ម៉ានឹងគាត់ស្លាប់កាលជំនាន់អាពតហើយ?

ខៈ ចាំ!បងប្អូនខ្ញុំនងបានស្លាប់នៅជំនាន់អាពតនឹងខ្លះ។

កៈ ចឹងម៉ាជាកូនទី២ហើយម៉ាថាស្លាប់២នាក់?

ខៈ ២នាក់នឹងទើបតែបានស្លាប់ដែល២ ៣ឆ្នាំនឹងទេ។

កៈ អរចឹងតើគាត់ស្លាប់ដោយសារអ្វីដែលម៉ា?

ខ៖ គាត់ឈឺនឹងណា។

ក៖ អរគាត់ឈឺអីគេដែលម៉ា?

ខ៖ គាត់ឈឺ។

ក៖ អរចឹងបងប្អូនទី៤មានឈ្មោះអ្វីដែលម៉ា?

ខ៖ ប្អូនទី៤ឈ្មោះ ញ៉ាម។

ក៖ ឈ្មោះញ៉ាមហើយទី៥ម៉ា?

ខ៖ ទី៥នៅកោះដាច់។

ក៖ អរនៅកោះដាច់ចឹងតើគាត់មានឈ្មោះអ្វីដែលម៉ា?

ខ៖ប្អូនខ្ញុំ ទី៥ឈ្មោះ សិន។

ក៖
ឈ្មោះសិនបាទចឹងម៉ាមាននៅចាំសាច់រឿងជាមួយពួកគាត់ទេម៉ាដូចជាធ្លាប់លំបាកជាមួយគ្នាសប្បាយជាមួយគ្នាចឹងណាស់ម៉ាតើមាននៅចាំទេម៉ា?

ខ៖ ខ្ញុំអត់សូវចាំទេ។

ក៖ អរម៉ាអត់ចាំទេដូចថាម៉ាធ្លាប់ទៅណាជាមួយគ្នាធ្លាប់ធ្វើស្រែធ្វើចំការជាមួយគ្នាអត់ម៉ា?

ខ៖ ខ្ញុំអត់សូវចាំដែល។

ក៖ អរម៉ាអត់សូវចាំដែលម៉ា?

ខ៖ ធ្លាប់ធ្វើចំការគេជំលៀស៣ឆ្នាំ៨ខែ១០ថ្ងៃ(សម័យអាពត)នៅវិហារសួរ។

ក៖ អរម៉ាធ្លាប់នៅវិហារសួរ?

ខ៖ ចាំ!គេជំលៀសខ្ញុំកាលនឹងទៅវិហារសួរនឹងខ្ញុំនឹង។

ក៖ អរគេជំលៀលម៉ាទៅខាងនឹងម៉ា?

ខ៖ ចាំ!

ក៖ បាទ!ចឹងកាលជំនាន់នឹងតើម៉ាមានអាយុប៉ុន្មានហើយម៉ា?

ខ៖ អេខ្ញុំផ្លេចហើយកាលនឹងជាង៥០ឆ្នាំហើយ។

ក៖ អរចឹងកាលជំនាន់អាពតនឹងម៉ាអាយុជាង៥០ឆ្នាំហើយ?

ខ៖ ចា៎!ខ្ញុំរាល់ថ្ងៃនឹងខ្ញុំបានភ្លេចខ្លះហើយមិនបាននៅចាំទេដោយសារតែខ្ញុំនឹងចាស់

ក៖ អរ?

ខ៖ គេជំលៀសខ្ញុំទៅ៣ឆ្នាំ៨ខែ២០ថ្ងៃកាលនឹងបានខ្ញុំមកស្រុកវិញ។

ក៖ បាទ!ចឹងពេលនឹងតើគេអោយម៉ាធ្វើអីគេដែលពេលគេជំលៀសនឹងម៉ា?

ខ៖
គេអោយធ្វើស្រែនឹងហើយស្រុកនឹងអត់ចេះធ្វើស្រែទេកាលនឹងធ្វើស្រែដក់ស្រូវស្ទូងនឹងគេនឹងឯងនឹងទៅដល់ពេល៣ឆ្នាំ៨ខែ២០ថ្ងៃនឹងមកបានគេអោយមកស្រុកវិញមក។

ក៖ បាទ!អរគេអោយម៉ានឹងមកស្រុកយើងមកស្រុកវិញមក?

ខ៖ ៣ឆ្នាំ៨ខែ២០ថ្ងៃ។

ក៖ បាទ!ទល់គេរំដោះបានទៅបានគេអោយយើងមកស្រុកវិញមក?

ខ៖ ចា៎!មកស្រុកវិញមកផ្ទះវិញមក។

ក៖ បាទ!ចឹងម៉ាទៅជាមួយឪពុកម្ដាយឬក៏អត់ទេម៉ា?

ខ៖
ឪពុកម្ដាយខ្ញុំកាលនឹងគាត់បានស្លាប់ហើយចឹងខ្ញុំមិនបានរស់នៅជានឹងកាត់ទេខ្ញុំជាកូនដែលបានកំព្រានឹងជាមួយនឹងបងប្អូនខ្ញុំនឹង។

ក៖ អរចឹងលោកឪពុករបស់ម៉ាកាលនឹងគាត់នឹងបានស្លាប់ហើយ?

ខ៖
អត់ទេឪពុកខ្ញុំកាលនឹងគាត់បាននៅរស់ទេគាត់នៅដែលជាមួយនឹងខ្ញុំដែលកាលនឹងហើយខ្ញុំនឹងបានកំព្រាតែម្ដាយទេឪពុកនឹងគាត់បានរស់ទេកាលនឹងណាចៅ។

ក៖ អរបាទ!នៅទាំងអស់គ្នា?

ខ៖
ពេលដែលបានមកវិញនឹងបានគាត់នឹងបានស្លាប់មកដល់ផ្ទះវិញបានគាត់ស្លាប់នៅផ្ទះវិញទេ។

ក៖ អរនៅពេលដែលបែកទៅបានគាត់ចែកឯានទៅ?

ខ៖ ចាំ!កាលនឹងនៅទេមិនអីទេកាលនឹងឪពុកខ្ញុំហើយនឹងម្ដាយណាកាលនឹង។

ក៖ បាទ!ចឹងម៉ាអត់មានអនុស្សវរីអ្វីជាមួយបងប្អូនទេ?

ខ៖ អត់មានទេបងប្អូនខ្ញុំកាលនឹងស្រលាញ់គ្នាណាស់។

ក៖ អត់ទេជាមួយបងប្អូនបង្កើតណាស់ម៉ា?

ខ៖ បងប្អូនខ្ញុំអត់មានទាស់ទែងគ្នាអីទេ។

ក៖ អត់ទេម៉ាដូចថាអនុស្ស

វរីធ្លាប់រត់កាលជំនាន់អាពតជាមួយគ្នាចឹងណាស់ម៉ា?

ខ៖ កាលនឹងបានរស់នៅទៅជាមួយគ្នានឹងមិនបានបែកគ្នាទេកាលនឹង។

ក៖ បាទ!ចឹងមានធ្លាប់ឈ្លួសគ្នាទេម៉ា?

ខ៖
ធ្លាប់មានទាស់គ្នាហើយបងប្អូនពីណាគេដែលមិនទាស់គ្នាណាចៅតែកាលនឹងវាទិចមិនបានដល់ថ្នាក់ធំដំទេកាលនឹង។

ក៖ បាទ!ចឹងម៉ាការងាររបស់ម៉ានឹងតាំងពីក្មេងមកម៉ាមានធ្លាប់ចំការចឹងទៅ?

ខ៖ ធ្វើចំការចឹងទៅហើយបាមដាំបន្លែកដែលនឹងកាលនឹង។

ក៖ បាទ!ធ្វើចំការចឹងទៅ?

ខ៖
នឹងហើយបន្តបមកទៅធ្វើស្រែដែលខ្ញុំមិនដែលនឹងបានទំនេរដែលនឹងកាលនឹងចុះកាលនឹងយើងនឹងវាអត់ណា។

ក៖ បាទ!ចឹងម៉ាបានចេះដាំថ្នាំនេះម៉ាចេះពីណាគេដែលម៉ា?

ខ៖
ធ្វើពីក្មេងមកចឹងម៉ងធ្វើថ្នាំឪពុកម្ដាយខ្ញុំនឹងគាត់ជាអ្នកដែលបានដាំថ្នាំក្រតាបតាំងពីឪពុកម
កណាចឹងបានជាខ្ញុំនឹងចេះដាំនឹង។

ក៖ អរបាទ!

ខ៖
ស្រុកស្រែគេធ្វើស្រូវតែស្រុកកោះនឹងគេធ្វើចំការខ្លះចឹងទៅហើយបានដាំថ្នាំខ្លះចឹងទៅណា
តាមតែគេធ្វើ។

ក៖ បាទ!ចាំថ្នាំផងចឹងទៅហើយបានធ្វើចំការខ្លះចឹងទៅបានចាំពូតខ្លះចឹងទៅណាម៉ា?

ខ៖
ដាំជំឡូងត្រាវដាំជំឡូងដាំទៅដាំថ្នាំដាំអីក៏បានដែលអោយតែយើងនឹងខំធ្វើចឹងណាទៅ។

ក៖ បាទ!

ខ៖
នៅស្រុកនឹងអត់មានស្រែធ្វើទេធ្វើតែបន្លែកខ្លះចឹងទៅហើយបានដាំពូតចឹងទៅបើធ្វើស្រែទ
ល់តែនៅភូមិមួយទៀតបានគេនឹងចូលចិត្តធ្វើតែស្រែនឹងណា។

ក៖ បាទ!ដោយសារដីនៅនឹងអត់មានជីវជាតិមែនម៉ា?

ខ៖ អត់ទេដីនឹងដីផ្សារអត់មានដីធ្វើស្រែផងនឹង។

ក៖ បាទ!ចឹងអត់មានដីធ្វើស្រែមានដីធ្វើចំការ?

ខ៖ អត់មាន។

ក៖ បាទ!ចឹងកាលម៉ានៅពីក្មេងជាមួយបងប្អូនរបស់ម៉ាតើម៉ាចូលចិត្តធ្វើអ្វីខ្លះជាមួយគ្នាម៉ា?

ខ៖ មានតាធ្វើចំការនឹង។

ក៖ អរបាទ!មានតែធ្វើចំការជាមួយគ្នាទេជួយឪពុកម្ដាយម្នាក់មួយដៃមួយជើងទៅម៉ា?

ខ៖ នឹងហើយ។

ក៖ បាទ!ចឹងម៉ាតើម៉ាមាននៅចាំឈ្មោះឪពុកម្ដាយរបស់ម៉ាទេ?

ខ៖ ខ្ញុំនៅចាំតើ។

ក៖ បាទ!ចឹងតើអ្នកម្ដាយគាត់មានឈ្មោះអ្វីដែលម៉ា?

ខ៖ ម្ដាយខ្ញុំឈ្មោះ មិត្ត។

ក៖ ឈ្មោះ មិត្តហើយចុះលោកឪពុកម៉ា?

ខ៖ លោកឪពុកឈ្មោះឆើម។

ក៖
បាទ!លោកឪពុកឈ្មោះឆើមបាទចឹងតើម៉ាមាននៅចាំថាពេលគាត់បានស្លាប់នឹងតើគាត់នៅមានអាយុប៉ុន្មានដែលម៉ា?

ខ៖ ឪពុកខ្ញុំស្លាប់អាយុ៨៩ឆ្នាំ។

ក៖ បាទ!នឹងលោកឪពុកស្លាប់អាយុ៨៩ឆ្នាំចុះអ្នកម្ដាយម៉ា?

ខ៖ ដូចគ្នាលោកឪពុកស្លាប់អាយុ៨៩ឆ្នាំអ្នកម្ដាយស្លាប់អាយុ៨៩ឆ្នាំដែល។

ក៖ បាទ!តែអ្នកម្ដាយរបស់ម៉ាគាត់ស្លាប់មុនលោកឪពុក?

ខ៖ អត់ទេលោកឪពុកខ្ញុំគាត់ស្លាប់មុនអ្នកម្ដាយខ្ញុំ។

ក៖ អរបាទ!លោកឪពុកម៉ាស្លាប់មុនអ្នកម្ដាយរបស់ម៉ា?

ខ៖ ចាំ!ឪពុកខ្ញុំបងម្ដាយខ្ញុំម៉ារជួរ។

ក៖ អរបាទ!ចឹងប៉ារបស់ម៉ាបងម្ដាយរបស់ម៉ាមួយជួរណាស់ម៉ា?

ខ៖ ចាំ!ឪពុកខ្ញុំនឹងគាត់បងម្ដាយខ្ញុំ១២ឆ្នាំ។

ក៖ អរបាទ!ចឹងម៉ាមានចាំឆ្នាំកំណើតរបស់ឪពុកម្ដាយរបស់ម៉ាទេ?

ខ៖ អត់ទេខ្ញុំមិនបានចាំទេកាលនឹងគាត់មិនដែលបានប្រាប់ខ្ញុំផងនឹងចឹងខ្ញុំមិនបានដឹង។

ក៖ បាទ!ចឹងឆ្នាំខ្មែរយើងតើម៉ាមាននៅចាំទេ?

ខ៖ ខ្ញុំអត់ដឹងសោះ។

ក៖ អរបាទ!គាត់អត់មានប្រាប់ម៉ាទេម៉ា?

ខ៖ អត់បានប្រាប់ខ្ញុំផងនឹងខ្ញុំដឹងថាគាត់អាយុ៨៩ឆ្នាំនឹងគាត់ស្លាប់។

កៈ អរបាទ!ចឹងម៉ាមានដឹងទីកន្លែងកំណើតរបស់គាត់ទេស្រុកកំណើតរបស់គាត់ណាស់ម៉ា?

ខៈ ស្រុកកំណើតគាត់នៅនឹង។

កៈ គាត់នៅនឹងគាត់ជាអ្នកស្រុកនឹងតែម្តង?

ខៈ ចាំ!គាត់ជាអ្នកស្រុកនឹងខ្ញុំបានធំដឹងក្តីមកខ្ញុំជាអ្នកដែលបានរស់នៅស្រុកនឹងតែម្តង។

កៈ បាទ!ចឹងទាំងអ្នកម្តាយទាំងលោកឪពុក?

ខៈ ចាំ!នៅនឹងទាំងអស់គ្នា។

កៈ អរនៅនឹងទាំងអស់គ្នានៅកោះនឹង?

ខៈ ចាំ!

កៈ ដូចថាអ្នកនៅក្នុងភូមិជាមួយគ្នាពេលឃើញគ្នាក៏ស្រលាញ់គ្នាទៅម៉ា?

ខៈ ចាំ!

កៈ
បាទ!ចឹងតើម៉ាមាននៅចាំថាឪពុកម្តាយរបស់ម៉ាតើពួកគាត់ប្រកបមុខរបរអ្វីដើម្បីចិញ្ចឹមម៉ា ហើយនឹងប្អូនរបស់ម៉ាកាលនៅតូចៗណាស់ម៉ា?

ខៈ នឹងធ្វើចំការនឹងម៉ងមិនបានធ្វើអីទេកាលនឹង។

កៈ ធ្វើថ្នាំធ្វើអីចឹងទៅម៉ា?

ខៈ ធ្វើថ្នាំដាំដំឡូងត្រាវអីចឹងទៅ។

កៈ អរចឹងគាត់អត់មានស្រវថ្នាំខ្លួនឯងទេម៉ា?

ខៈ អត់ថ្នាំអត់ស្រវទេហាន់ហារចឹងទៅ។

កៈ យកមកហាន់រួតហើយយកមកហារចឹងទៅ?

ខៈ ចាំ!រួតហើយយកទៅលក់ទៅ។

កៈ អរបាទ!

ខៈ ដាំដំឡូវត្រាវយកទៅលក់ទៅ។

កៈ បាទ!ចឹងយកទៅលក់នៅណាដែលម៉ា?

ខៈ យកទៅលក់នៅភ្នំពេញទៅយកទៅលក់នៅព្រែកផ្ទៅអីចឹងទៅ។

កៈ អរចឹងដើរលក់ទៅ?

ខៈ ចាំ!ដើរលក់ទៅ។

កៈ បាទ!ចឹងអត់មានបោះអោយមួយទេម៉ា?

ខៈ អត់ទេថ្នាំតិចទូចនឹងមានអីបោះអោយគេ។

កៈ
បាទ!នេះគ្រាន់តែយើងលក់យកប្រាក់មកដោះស្រាយជីវភាពទេហើយនឹងកុំអោយយើងទំនេ?

ខៈ ចាំ!ធ្វើតិចតួចនឹង។

កៈ បាទ!ធ្វើកំអោយមានជំងឺ?

ខៈ អត់ទេបើមិនរកយើងបានអីហូប។

កៈ បាទ!ម៉ាចំពោះម៉ាតើម៉ាគិតថាឪពុកម្ដាយរបស់ម៉ាតើគាត់ជាមនុស្សកាចឬមួយក៏ស្លូតម៉ា?

ខៈ គាត់ស្លូតទេ។

កៈ គាត់ស្លូតទេម៉ា?

ខៈ ចាំ!

កៈ ចឹងគាត់អត់ដែលវៃម៉ាទេ?

ខៈ អត់ដែលវៃទេ។

កៈ បាទ!ចឹងម៉ាមានដែលខូតទេម៉ា?

ខៈ អត់មានទេ។

កៈ បាទ!ចឹងម៉ាមានដែលរឹងអោយគាត់វៃទេ?

ខៈ អទ់ទេខ្ញុំអត់ដែលរឹងទេ។

កៈ បាទ!ម៉ាស្តាប់ឪពុកម្តាយ?

ខៈ ចាំ!ខ្ញុំស្តាប់ឪពុកម្តាយណាស់មិនដូចក្មេងឥឡូវទេរពិបាកណាស់។

កៈ បាទ!ក្មេងឥឡូវពិបាកស្តាប់ម៉ា?

ខៈ នឹងហើយក្មេងពីដើមស្តាប់ឪពុកម្តាយណាស់។

កៈ បាទ!ចឹងអ្នកម្តាយរបស់ម៉ាស្លូតដែល?

ខៈ ចាំ!គាត់ស្លូតណាស់។

កៈ បាទ!ចឹងអ្នកម្តាយហើយនឹងលោកឪពុកគាត់ជាអ្នកធ្វើចំការទាំងអស់គ្នាទៅ?

ខៈ ចាំ!គាត់ជាអ្នកធ្វើចំការទាំងអស់គ្នានៅស្រុកនឹងអត់មានស្រែអោយធ្វើទេ។

កៈ បាទ!ធ្វើចំការទាំងអស់គ្នា?

ខៈ ចាំ!ធ្វើចំការទាំងអស់គ្នា។

កៈ បាទ!ចឹងមិនមែនអ្នកម្តាយរបស់ម៉ាជាមេផ្ទះទេ?

ខៈ គាត់ត្បាញធ្វើចំការទៅ។

កៈ អរអ្នកម្តាយរបស់ម៉ាចេះត្បាញទៀត?

ខៈ គាត់ត្បាញចឹងទៅ។

កៈ អរគាត់ត្បាញហូលផាមួងក្រមារចឹងទៅ?

ខៈ ចាំ!ធ្វើអោយតាម៉ារស់ៗនឹងមានអ្នកមានអី។

កៈ បាទ!ពិននឹងបានហើយអោយតាមានសុភមង្គរម៉ា?

ខៈ ចាំ!តាគេមានគេស្រុកហើយយើងក្រពិបាកហើយ។

កៈ បាទ!វាមិនពិបាកទេអោយតាជីវិត្តយើងនៅរស់យើងតស៊ូទៅគំតែរីកចំរើនទេម៉ា?

ខៈ គេមានគេស្រួលណាស់អ្នកក្រពិបាកហើយ។

កៈ គេថាក្រអីក្រទៅកុំអោយតែក្រចិត្តម៉ា?

ខ៖ ចាំ!

ក៖ បាទ!ចឹងម៉ាតើម៉ាមាននៅចាំសាច់រឿងអ្វីខ្លះជាមួយឪពុកម្តាយរបស់ម៉ាទេ?

ខ៖ អត់ទេខ្ញុំអត់ចាំផងនឹង។

ក៖
បាទ!ចឹងម៉ាមាននៅចាំថាធ្លាប់ទៅធ្វើចំការជាមួយគ្នាអីទៅណាជាមួយគ្នាអីតើម៉ាមាននៅចាំទេម៉ា?

ខ៖ ខ្ញុំអត់សូវចាំទេ។

ក៖ អរបាទ!ម៉ាអត់សូវចាំទេម៉ា?

ខ៖ ចាំ!

ក៖
បាទ!ចឹងម៉ាតើគាត់មានដែលនិយាយប្រាប់ម៉ាអំពីខ្សែជីវិត្តរបស់គាត់ការនៅពីក្មេងអោយម៉ាស្តាប់ទេម៉ា?

ខ៖ គាត់ចេះតែប្រាប់យើងថាអោយយើងខំប្រឹងរក់ស៊ីទៅណាស់ពិននឹង។

ក៖ បាទ!គាត់ប្រាប់អោយយើងខំប្រឹងរៀនសូត្រទៅ?

ខ៖ អត់បានរៀនទេកាលជំនាន់ខ្ញុំអត់បានរៀនផងនឹង។

ក៖ អរចឹងម៉ាកើតជំនាន់លន់នល់មែនម៉ា?

ខ៖ មិនមែនជំនាន់លន់នល់ទេ។

ក៖ ចឹងមុនលន់នល់ទៀត?

ខ៖ ចាំ!

ក៖ បាទ!ចឹងជំនាន់សម្តេចឪ?

ខ៖ នឹងកាលជំនាន់សម្តេចឪ។

ក៖ បាទ!ចឹងពេលជំនាន់សម្តេចឪនឹងតើម៉ាមានអាយុប៉ុន្មានឆ្នាំហើយម៉ា?

ខ៖ ខ្ញុំចង់ភ្លេចអស់ហើយនេះ។

កៈ ១៧ ១៨ឆ្នាំម៉ា?

ខៈ អត់ទេចូលចិត្ត២០ ៣០ឆ្នាំហើយ។

កៈ អរម៉ាមានអាយុ២០ ៣០ឆ្នាំហើយដល់ពេលជំនាន់លន់នល់ម៉ាមានអាយុ៥០ឆ្នាំអីហើយនឹងដល់ពេលចូលជំនាន់អាពតម៉ាចូល៥០ឆ្នាំជាង?

ខៈ អត់ទេជំនាន់អាពតចូល៥០ឆ្នាំ។

កៈ អរចឹងជំនាន់លន់នល់ម៉ាចូល៤០ឆ្នាំជាង?

ខៈ ចាំ!ចូល៤០ឆ្នាំជាងហើយវាមិនចាំនឹងណាស់អ្នកណាអង្គុយតាចាំបើរវល់តែរកស៊ីពេកចង់ភ្លេចអស់ហើយ។

កៈ បាទ!ចឹងម៉ារកស៊ីអីគេដែលម៉ា?

ខៈ រកស៊ីធ្វើចំការនឹងមានរកស៊ីអីស៊ីឈ្នួលគេខ្លះទៅ។

កៈ បាទ!ចឹងម៉ាធ្លាប់ស៊ីឈ្នួលគេដែលម៉ា?

ខៈ ស៊ីឈ្នួលធ្វើកាណូតអោយគេទៅណាស់។

កៈ អរម៉ាចេះធ្វើកាណូតទៀត?

ខៈ អត់ទេប្តីខ្ញុំទេខ្ញុំអត់ទេ។

កៈ អរប្តីរបស់ម៉ាបាទចឹងតើម៉ាមានចាំឈ្មោះជីដូនជីតារបស់ម៉ាទេដូចថាខាងឪពុកខាងម្តាយគុងម៉ារបស់ខាងឪពុកចឹងណាស់តើគាត់មានឈ្មោះអីគេដែលម៉ា?

ខៈ ជីតាខ្ញុំចាំគាត់ឈ្មោះ តាមិន យាយឈ្មោះ តែ។

កៈ អរលោកតាឈ្មោះ មិន លោកយាយឈ្មោះ តែនឹងខាងឪពុកណាម៉ា?

ខៈ ខាងខ្ញុំម៉ង។

កៈ អរខាងរបស់ម៉ានឹងតើខាងឪពុកឬមួយខាងម្តាយម៉ា?

ខៈ ខាងម្តាយ។

កៈ អរខាងម្ដាយម៉ា?

ខៈ ចាំ!ខាងម្ដាយ។

កៈ បាទ!ចឹងខាងឪពុកតើម៉ាមាននៅចាំទេម៉ា?

ខៈ អត់ចាំទេ។

កៈ បាទ!ចឹងម៉ាចាំតាខាងម្ដាយ?

ខៈ ចាំ!

កៈ ម៉ាស្រលាញ់ខាងម្ដាយជាងម៉ា?

ខៈ អត់ទេខ្ញុំមកនៅជាមួយគាត់។

កៈ អរម៉ាមកនៅមកនៅជាមួយគាត់ហើយចុះខាងឪពុកអត់មកនៅជាមួយម៉ាទេ?

ខៈ អត់ផងនឹង។

កៈ អរចឹងគាត់អត់នៅជាមួយម៉ាទេគាត់ចែលឯានមុនឬក៏មិចដែលម៉ា?

ខៈ អត់ទេនៅជាមួយគ្នាតែខ្ញុំចាំតាឈ្មោះខាងម្ដាយខ្ញុំនឹង។

កៈ ខាងលោកឪពុកម៉ាអត់ចាំទេ?

ខៈ អត់ចាំសោះមកនៅខាងយាយខ្ញុំ។

កៈ អរឪពុករបស់ម៉ាមកនៅខាងម្ដាយរបស់ម៉ា?

ខៈ ចាំ!

កៈ បាទ!ចឹងបានម៉ាចាំបាទចឹងតើគាត់មានដែលវៃម៉ាទេម៉ា?

ខៈ អត់ទេ។

កៈ អត់ទេគុងហើយនឹងម៉ាស្រលាញ់ម៉ាជាកូនទៅ២តែម៉ាស្លូត?

ខៈ ចាំ!

កៈ បាទ!ចឹងតើម៉ាមានបានដឹងថាឆ្នាំខ្មែរយើងគាត់កើតឆ្នាំណាដែលម៉ា?

ខ៖
ខ្ញុំអត់ដឹងថាគាត់កើតឆ្នាំអីទេព្រោះការនឹងខ្ញុំនៅតូចៗនឹងខ្ញុំមានដឹងអីឃើញគាត់ហៅតាហៅយាយនឹង។

ក៖
បាទ!ម៉ានៅក្មេងបាទចឹងម៉ាជាអ្នករស់នៅខេត្តកណ្ដាលភូមិកោះឧញ្ញាតីនឹងតាំងពីម៉ាកើតមក?

ខ៖ ចាំ!ខ្ញុំនៅនឹងតាំងពីខ្ញុំកើតមកម្លេះខ្ញុំនៅនឹងម៉ង។

ក៖
អរបាទ!ចឹងម៉ាកើតនៅនឹងម៉ងបាទចឹងតើម៉ាមានបងប្អូនជីតូចមួយជីដូនមួយដែលពួកគាត់ទៅរស់នៅស្រុកក្រៅទេម៉ា?

ខ៖ អត់មានទេបើមានបងប្អូននៅស្រុកក្រៅមានបាត់ហើយ។

ក៖ បាទ!ចឹងបច្ចុប្បន្ននឹងអត់មានដែលម៉ា?

ខ៖ អត់មានទេ។

ក៖ អរមានចៅតូចចៅអីគាត់ទៅធ្វើការនៅថៃអីចឹងណាស់?

ខ៖ អត់មានទេ។

ក៖ បាទ!ចឹងទៅប្រទេសគូរេអីក៏អត់មានដែលម៉ា?

ខ៖ អត់មានទេ។

ក៖
បាទ!ចឹងម៉ាបើនិយាយពីអាពិហ៍ពិពាហ៍របស់ម៉ានឹងតើស្វាមីរបស់ម៉ាមានឈ្មោះអ្វីដែលម៉ា?

ខ៖ គាត់ឈ្មោះ ញ៉េញ។

ក៖ អរគាត់ឈ្មោះ
ញ៉េញបាទចឹងម៉ារៀបការជាមួយស្វាមីរបស់ម៉ានឹងតើបានប៉ុន្មានឆ្នាំហើយម៉ា?

ខ៖ អរអត់ដឹងទេភ្លេចអស់ហើយ។

ក៖ បាទ!តាំងពីជំនាន់ណាដែលម៉ា?

ខ៖ តាំងពីជំនាន់សម្ដេចឪមកម្លេះ។

ក៖ អរតាំងពីជំនាន់សម្ដេឪមកចឹងចង់៥០ឆ្នាំជាងហើយ?

ខ៖ ចា៎!ការជំនាន់សម្ដេចកំពង់សប្បូសប្បាយ។

ក៖ អរជំនាន់កំពង់តែសប្បូសប្បាយបាទចឹងម៉ាការនៅណាដែលម៉ា?

ខ៖ ខ្ញុំការនៅផ្ទះនឹងផ្ទះម៉ែខ្ញុំនៅមុខនឹង។

ក៖
អរបាទ!ចឹងអាពិហ៍ពិពាហ៍របស់ម៉ាតើឪពុកម្ដាយគាត់ជាអ្នកផ្សំផ្គុមអោយឬមួយម៉ាឃើញគ្នាស្រលាញ់គ្នាដោយខ្លួនឯងម៉ា?

ខ៖
អត់ទេកាលនឹងមានតាម៉ែឪទេជាអ្នកផ្សំផ្គុមអោយមិនដូចជំនាន់យើងឥឡូវណាជំនាន់ខ្ញុំអត់ទេ។

ក៖ អរបាទ!ជំនាន់ឥឡូវគេឃើញគ្នាទៅគេរៀបការ?

ខ៖ ចា៎!កាលនឹងអត់ទេតាស្រលាញ់គ្នាសែនហើយជំនាន់ខ្ញុំណាស់។

ក៖ បាទ!

ខ៖ អត់មានស្រលាញ់គ្នាហើយការទេ។

ក៖ បាទ!ឪពុកម្ដាយគាត់ជាអ្នករៀបចំអោយទៅ?

ខ៖ ចា៎!ស្រែកតាឪពុកហើយនឹងម្ដាយគាត់ជាអ្នករើសទេ។

ក៖ បាទ!ចឹងម៉ាពេលនឹងម៉ាមានដែលជួបគុងទេ?

ខ៖ អត់ទេមិនដែលស្គាល់គ្នាមិនដែលនិយាយរកគ្នាផងនឹង។

ក៖ អរបាទ!ចឹងម៉ាមានដឹងថាគុងគាត់នៅខេត្តណាទេម៉ា?

ខ៖ គាត់នៅស្រែ។

ក៖ គាត់នៅស្រុកណាដែលម៉ា?

ខ៖ ឪពុកគាត់នៅនឹងម្ដាយគាត់នៅស្រែ។

កៈ អរម្ដាយគាត់នៅខាងស្រុកស្រែ?

ខៈ ចា៎!

កៈ បាទ!ចឹងម៉ាមិនដែលជួបគ្នាទេគឺឪពុកម្ដាយគាត់ជាអ្នកផ្សំផ្គុំអោយ?

ខៈ ចា៎!

កៈ បាទ!ចឹងម៉ាពេលម៉ារៀបការនឹងម៉ាឃើញគាត់តើម៉ាមានអារម្មណ៍មិចដែលម៉ា?

ខៈ មានអារម្មណ៍ស្រលាញ់នឹងបាននៅជាមួយគ្នាកើត។

កៈ បាទ!ពេលអត់ទាន់ការ?

ខៈ ខ្ញុំអត់ដឹងអីទេ។

កៈ ពេលរៀបចំនឹងម៉ាអត់ដឹងទេ?

ខៈ ដល់ពេលយើងការរួតទៅម្ដាយគាត់ថាអោយខ្ញុំស្រលាញ់គ្នាដល់ឥឡូវទៅ។

កៈ បាទ!ធ្វើមិចបើយើងការហើយបើយើងបែកគ្នាក៏វាពិបាកដែលម៉ា?

ខៈ នឹងហើយ។

កៈ បាទ!ចឹងចេះតែតស៊ូនៅជាមួយគ្នាទៅ?

ខៈ ចា៎!

កៈ បាទ!ចឹងម៉ាពេលដែលម៉ាការហើយតើម៉ាប្រកបមុខរបរអ្វីម៉ា?

ខៈ អត់មានធ្វើអីទេធ្វើតាចំការនឹង។

កៈ ធ្វើតាចំការនឹងតាមួយមុខទេម៉ា?

ខៈ នឹងហើយមានធ្វើអី។

កៈ បាទ!ចឹងម៉ាពេលរៀបការជាមួយស្វាមីម៉ានឹងតើម៉ាមានកូនប៉ុន្មាននាក់ដែលម៉ា?

ខៈ ខ្ញុំបានកូនតាមួយនឹង។

កៈ អរម៉ាបានកូនតាមួយទេ?

ខ៖ ចាំ!

ក៖ កូនស្រីកូនប្រុសម៉ា?

ខ៖ កូនប្រុសឥឡូវស្លាប់បាត់ហើយ។

ក៖ ស្លាប់ហើយម៉ា?

ខ៖ ចាំ!

ក៖ ហើយបងស្រីនៅខាងមុខនឹងត្រូវជាអ្វីជាមួយម៉ាដែល?

ខ៖ ត្រូវជាកូនប្រសារ។

ក៖ អរកូនប្រសារ?

ខ៖ ចាំ!កូនខ្ញុំគាត់ស្លាប់បាត់ហើយ។

ក៖ អរចឹងគាត់ស្លាប់ដោយសារអ្វីដែលម៉ា?

ខ៖ ឈឺ។

ក៖ អរគាត់ឈឺគាត់កើតជំងឺអីគេដែលម៉ា?

ខ៖ ខ្ញុំមិនដឹងវាឈឺអីៗទេ។

ក៖ មហារីកមែនម៉ា?

ខ៖ អត់ទេ។

ក៖ ចឹងគាត់ឈឺជាជំងឺប្រចាំខ្លួនម៉ា?

ខ៖ នឹងហើយ។

ក៖ បាទ!ចឹងពេលដែលម៉ារៀបការនឹងតើគុងគាត់បានផ្តលចំនួនអោយម៉ាប៉ុន្មានដែលម៉ា?

ខ៖ អរតិចតួចទេកាលនឹងគ្មានចំនួនអីដូចឥឡូវទេ។

ក៖ បាទ!ប៉ុន្មានដែលម៉ាបន្តិចបន្តួចនឹងម៉ាប្រហែលប៉ុន្មានដែលម៉ា?

ខ៖ ២ពាន់។

ក៖
២ពាន់ហើយតិចតួចទៀតម៉ាពេលនឹងស្អាតហើយបាន២ពាន់បាទការនឹងតើម៉ាមានអាយុប៉ុន្មានដែលម៉ា?

ខ៖ ខ្ញុំជាង២០ឆ្នាំហើយ។

ក៖
អរជាង២០ឆ្នាំចឹងម៉ាស្អាត់ហើយបានគុងគាត់ស្រលាញ់ម៉ាបាន២ពាន់កាលនឹងប៉ុន្មានតុកដែលម៉ា?

ខ៖ កាលនឹងអត់មានតុកអត់មានអីទេ។

ក៖ អរលក្ខណះថាហៅបងប្អូនមកហូបធម្មតាទៅ?

ខ៖ ចាំ!អត់មានតុកអីដូចឥឡូវនឹងទេ។

ក៖ បាទ!ចឹងបើនិយាយពីភាសាខ្មែរយើងតើម៉ាអាចចេះសរសេរអានបានទេម៉ា?

ខ៖ អត់ទេខ្ញុំអត់ចេះម៉ងនឹង។

ក៖ អរម៉ាអត់បានចូលរៀនសោះម៉ងម៉ា?

ខ៖ អត់បានសោះម៉ង។

ក៖ បាទ!ដោយសារជីវភាពគ្រួសារមានការពិបាក?

ខ៖
ចាំ!អត់បានរៀនទេខ្ញុំនិងព្រោះអីគ្រួសារខ្ញុំក្រហើយអត់មានលុយឲ្យរៀនអញ្ជឹងណាស់ក្មួយអើយ។

ក៖
បាទ!ហើយអញ្ជឹងម៉ាអត់ចេះទេភាសាខ្មែរនោះហើយអញ្ជឹងម៉ាបើក្រោយពីភាសាបរទេសដូចជាភាសាអង់គ្លេស បារាំង អីម៉ាមានចេះទេ?

ខ៖ ខ្ញុំអត់ចេះទេព្រោះខ្ញុំអត់បានរៀនផងនិងហើយខ្ញុំអត់ចេះទេភាសាបរទេសនោះ។

ក៖ បាទ! ហើយអញ្ជឹងម៉ាអត់ចេះទេភាសាបរទេសនិងម៉ា។

ខ៖ ចាំ! ហើយខ្មែរខ្ញុំអត់បានរៀនផងនិងហើយខ្ញុំមានបានរៀនភាសាបរទេសទេ។

កៈ បាទ! ហើយអញ្ចឹងម៉ាអត់ចេះទេ។

ខៈ ចាំ!
អត់ចេះទេហើយសព្វថ្ងៃនិងបើខ្ញុំចេះខ្មែរនិងមានអីហើយភាសាបរទេសវាអត់សូវសំខាន់ទេហើយធំជាងគេនិងភាសាខ្មែរនិងហើយមានណាខ្ញុំអត់ចេះទេ។

កៈ បាទ!
ត្រូវហើយម៉ាធំជាងគេភាសាខ្មែរព្រោះអីយើងនៅខ្មែរហើយយើងជាជនជាតិខ្មែរណាម៉ាណោះ។

ខៈ ចាំ! ត្រូវហើយមានអីសំខាន់ជាងភាសាខ្មែរយើងទេ។

កៈ បាទ! បើអត់ចេះវាពិបាកហើយណាម៉ាណោះ។

ខៈ ចាំ!

កៈ
ហើយអញ្ចឹងម៉ាបើនិយាយពីមិត្តភក្តិរបស់កាលដែរម៉ានៅពីក្មេងហើយរហូតម៉ាធំពេញវ័យនិងតើម៉ាមានមិត្តភក្តិជិតស្និតប៉ុន្មាននាក់ដែរម៉ាហើយនៅស្រុកភូមិរបស់ម៉ា?

ខៈ
ហើយមិត្តភក្តិវាចេះតែមានហើយមិត្តភក្តិនោះហើយខ្ញុំដូចអត់សូវពឹនដើរដូចគេទេព្រោះអីខ្ញុំក្រហើយខ្ញុំពេលខ្លះខ្ញុំទៅធ្វើការនិងហើយអត់មានពេលដើរលេងទេដូចក្មេងឥឡូវនិងទេគេមានពេលដើរលេងហើយគេមានពេលទៅណាហើយខ្ញុំកាលណុងគ្មានទេនៅតែធ្វើការនិងគ្មានពេលណាថាបានសប្បាយដូចគេទេ។

កៈ បាទ!
ហើយអញ្ចឹងនៅក្នុងជីវិតរបស់ម៉ាមានការលំបាកជាច្រើនណាម៉ាហើយម៉ាអត់មានការសប្បាយចិត្តហើយអត់មានពេលស្រួលខ្លួនទេណាម៉ា។

ខៈ ចាំ!
ហើយខ្ញុំមានការលំបាកណាហើយខ្ញុំនិងមិនបានស្រួលទេមានជីវិតនិងហើយរហូតដល់ចាស់និងហើយនៅតែខំប្រឹងរកបេះស្លឹកថ្នាំហើយយកទៅលក់យកលុយខ្លះមកទុកអញ្ចឹងណាស់។

កៈ បាទ! ហើយអញ្ចឹងម៉ាកាលនិងម៉ាពេលដែរបានចេញពីរៀនមកផ្ទះគិតតែត្បាញម៉េងម៉ា?

ខៈ ចាំ! ហើយកាលនិងខ្ញុំអត់បានរៀនទេ។

កៈ បាទ! ហើយអញ្ចឹងម៉ាដូចមិត្តភក្តិនៅក្នុងភូមិនិងម៉ាមានមិត្តភក្តិនៅក្នុងភូមិទេ?

ខៈ បើនិយាយពីមិត្តភក្តិនៅក្នុងភូមិខ្ញុំវាចេះតែមានហើយមិត្តភក្តិនិង។

កៈ បាទ! ហើយអញ្ចឹងមានមិត្តភក្តិនៅក្នុងភូមិមានប៉ុន្មាននាក់ដែរម៉ា?

ខៈ ហើយមានអស់និងមានច្រើនឯណាមានតែបួនប្រាំនាក់អីនិងមានច្រើនណា។

កៈ បាទ! ហើយអញ្ចឹងម៉ាមានមិត្តភក្តិតែបួនប្រាំនាក់ទេម៉ាអត់មានច្រើនទេម៉ា?

ខៈ
ចាំ!អត់មានច្រើនទេនៅក្នុងភូមិនិងមានតែប៉ុណ្ណឹងមានណាច្រើនក្មេងៗវ័យគ្មានច្រើនទេ។

កៈ បាទ! ហើយអញ្ចឹងម៉ាមានចាំឈ្មោះពួកគាត់ទេម៉ា?

ខៈ ខ្ញុំអត់ចាំទេក្មួយអើយមានណាចាំឈ្មោះព្រោះឥឡូវចាស់ៗហើយនិងគ្មានបានចាំទេ។

កៈ បាទ!
ហើយអញ្ចឹងម៉ាអត់ចាំទេម៉ាហើយអត់ដឹងថាគាត់ឥឡូវនិងគាត់នៅកន្លែងណាទេម៉ា?

ខៈ
ខ្ញុំអត់ដឹងទេថាគេឥឡូវនិងគេនៅណាទេព្រោះអត់ដែរឃើញគ្នាហើយនិងអត់ដែររាបអានគ្នាផងនិង។

កៈ បាទ! ហើយអញ្ចឹងម៉ាទេដឹងទេណាម៉ាណោះ។

ខៈ ចាំ!

កៈ
បាទចឹងកាលនឹងម៉ាដែលបានចាំថាកាលនឹងម៉ាជាមួយនឹងមិត្តភក្តិរបស់ម៉ាកាលនឹងដែលបាននាំគ្នានឹងទៅរាំងវង់?

ខៈ អត់ទេខ្ញុំមិនដែលនឹងបានទៅរាំងចឹងទេខ្ញុំកាលនឹង។

កៈ បាទចឹងកាលនឹងម៉ាដែលបានធ្លាប់ដែលបានធ្វើអីនឹងជាមួយគ្នាទេកាលនឹងម៉ា?

ខៈ អត់ទេខ្ញុំមិនបានទៅណាទេខ្ញុំនឹង។

កៈ បាទដើរជាចឹងម៉ាមិនដែលបាននាំគ្នាដើរលេងទេកាលនឹងម៉ាណាម៉ា?

ខៈ ចាំខ្ញុំអត់ដែលចឹងទេខ្ញុំនឹង។

ក៖ម៉ាចឹងកាលនឹងម៉ាដែលបានស៊ីស្នួនដក់ស្ទួនអោយគេទេម៉ាកាលនឹង?

ខ៖
ចាំខ្ញុំធ្លាក់ដែលបានដើរស៊ីស្នូរអោយគេដែលកាលនឹងខ្ញុំនឹងបើមិនបានស៊ីស្នូរគេកាលនឹងយើងអត់មានលុយនឹងចោយក្នុងគ្រួសារយើងទេកាលនឹងហើយខ្ញុំកាលនឹងខ្ញុំនឹងបានចេះស្ទួនកាលនឹងខ្ញុំនឹង។

ក៖បាទកាលនឹងស៊ីស្នូរដក់ស្ទួនអោយគេនឹងម៉ាកាលនឹង?

ខ៖កាលនឹងចឹងទេដឹងខ្ញុំបានជាខ្ញុំនឹងបានចេះស៊ីស្នូរដក់ស្ទួនអោយគេនឹងកាលនឹងហើយខ្ញុំនឹងមិនដែលនឹងបានដក់ស្ទួននឹងទេតែពេលជំនាន់អាពតនឹងបានខ្ញុំនឹងបានចេះធ្វើស្រែកាលនឹងខ្ញុំនឹង។

ក៖បាទមកដល់ពេលនឹងបានខ្ញុំនឹងបានចេះធ្វើស្រែចឹងទៅណាខ្ញុំនឹង?

ខ៖
នៅនឹងខ្ញុំនឹងបានដាំតែពូតនឹងហើយនឹងបន្លែងទិចទួចនឹងនៅនឹងហើយដល់ទៅគេបាននាំគ្នានឹងដាំអំពៅចឹងទៅ។

ក៖ បាទចឹងកាលនឹងម៉ាបានប៉ុន្មានដែលម៉ាកាលនឹង?

ខ៖ កាលនឹងមិនបានច្រើនទេកាលនឹងបានតែទិចទួចកាលនឹង។

ក៖ ប្រហែលជាបានប៉ុន្មានដែលម៉ាកាលនឹង?

ខ៖ អត់ទេកាលនឹងខ្ញុំបានតែទិចទូចនឹងកាលនឹងបានតែម៉ាររស់ៗនឹងកាលនឹងខ្ញុំនឹង។

ក៖ បាទចឹងកាលនឹងម៉ាតែទិចៗចឹងណាម៉ាកាលនឹង?

ខ៖ នឹងហើយខ្ញុំបានតែទិចនឹងខ្ញុំកាលនឹង។

ក៖បាទចឹងម៉ាមិនបានដឹងថាម៉ាបានប៉ុន្មានទេកាលនឹងតែបានដឹងថាម៉ារចិញ្ចឹមជីវិតនឹងរស់ធម្មតានឹងណាម៉ាកាលនឹង?

ខ៖ចាំនឹងហើយខ្ញុំកាលនឹងខ្ញុំបានរកនឹងម៉ារចិញ្ចឹមធម្មតានឹងខ្ញុំកាលនឹងហើយខ្ញុំមិនបានជំពាក់គេរទេខ្ញុំនឹងបានតែម៉ារចិញ្ចឹមពោះនឹង?

ក៖
ចុះម៉ាតាំងពីម៉ាពីតូចមកដល់ពេលដែលម៉ានឹងមកដល់រាល់ថ្ងៃនឹងតើម៉ាដេលបានជួបនឹងកាលពិបាកហើយនឹងកាលនឹងសប្បាយដែលទេម៉ានៅក្នុងជិវិតរបស់ម៉ានឹង?

ខ៖ កាលនឹងខ្ញុំនឹងបានជួបដែលនឹងខ្ញុំកាលនឹងខ្ញុំនឹង។

ក៖
បាទចឹងកាលនឹងម៉ាដែលបានជួបនឹងកាងារអីខ្លះទៅម៉ាដែលម៉ាបានប្រាប់ខ្ញុំថាម៉ាបានជួបនឹងកាលពិបាកនឹងម៉ា?

ខ៖
ខ្ញុំកាលនឹងខ្ញុំមិនបានពិបាកអីនឹងខ្លាងទេកាលនឹងតែពិបាកខ្ញុំរកបានទៅខ្ញុំនឹងសប្បាយចឹងទៅណាខ្ញុំនឹងហើយបើខ្ញុំនឹងរកមិនបានខ្ញុំនឹងក៏ពិបាកចឹងទៅដូចដែលរាល់ថ្ងៃចឹងណាខ្ញុំនឹង។

ក៖
បាទចឹងម៉ាបានជួបនឹងកាលនឹងកាលពិបាកនឹងច្រើនដែលកាលនឹងម៉ាហើយដល់ពេលម៉ាដែលបានមានប្តីនឹងតើម៉ាកាលនឹងដែលបានជួបនឹងកាលដែលម៉ានឹងពិបាលអីខ្លះដែលម៉ា?

ខ៖
ខ្ញុំមិនបានពិបាកអីទេខ្ញុំពេលនឹងណាកូនខ្ញុំនឹងវាបានធំហើយចឹងខ្ញុំនឹងមិនបានពិបាកអីទេខ្ញុំរាល់ថ្ងៃនឹងខ្ញុំនឹងកាលដែលកូនខ្ញុំនឹងបាននៅពីតូចនឹងបានខ្ញុំនឹងពិបាលដែលកាលនឹងកូនខ្ញុំពេលវាបានឈឺអីចឹងទៅកាលនឹងខ្ញុំនឹងមិនបានមានលុយចឹងកាលនឹងអូពិបាកលេងនិយាយចេញហើយកាលនឹងខ្ញុំ។

ក៖ បាទចឹងម៉ាពិបាកខ្លាងណាស់ហើយកាលនឹងម៉ា?

ខ៖នឹងហើយកាលនឹងខ្ញុំនឹងសប្បាយខ្លះហើយនឹងខ្ញុំនឹងពិបាកនឹងខ្លះចឹងណាកាលនឹង។

ក៖បាទចឹងកាលនឹងម៉ាមិនបាននឹងសប្បាយទេកាលនឹងម៉ា?

ខ៖ សប្បាយក៏នឹងសប្បាយហើយពិបាកនឹងក័ពិបាកកាលនឹង។

ក៖
បាទចឹងម៉ាសប្បាយខ្លះហើយនឹងពិនាកនឹងខ្លះចឹងទៅម៉ាតែខ្លះចឹងទៅម៉ាកាលនឹងតែទុកនឹងវាបានច្រើនជាសប្បាយម៉ា?

ខ៖ ចាំ!នឹងហើយទុកនឹងវាបានមកច្រើនជាងសប្បាយទៀត។

ក៖
ហើយអញ្ចឹងដូចកុងនិងតើគាត់មានចរិតយ៉ាងមិចដែរម៉ា?ហើយអញ្ចឹងម៉ាកុងត្រូវជាប្តីរបស់ម៉ាតើគាត់មានចរិតបែបណាដែរម៉ា?

ខ៖ ចាំ!

ក៖ បាទ! ហើយដូចជាគាត់កាចឬក៏គាត់ស្លូតអញ្ចឹងម៉ា។

ខ៖ ចាំ! អត់ទេគាត់ស្លូតណាស់គាត់អត់កាចទេ។

ក៖ ហើយអញ្ចឹងគាត់ស្លូតណាម៉ាណោះ។

ខ៖ ចាំ! គាត់ស្លូតណាស់។

ក៖ បាទ!
ហើយអញ្ចឹងគាត់មានដែលកាចដាក់ម៉ាទេហើយអញ្ចឹងគាត់ស្រឡាញ់ម៉ាណាម៉ាណោះ។

ខ៖ ចាំ! បើមិនស្រឡាញគ្នាមិចអាចរស់នៅជាមួយគ្នាកើត។

ក៖ បាទ! ហើយអញ្ចឹងម៉ាបើនិយាយពីមុខម្ហូបតើម៉ាចូលចិត្តមុខម្ហូបអីជាងគេម៉ា?

ខ៖ ចាំ! គ្មានអីទេមានតែប្រហុកអំបិលអីចេះតែញ៉ាំទៅខ្ញុំអត់ដែររើសទេ។

ក៖ បាទ!

ខ៖ ហើយក្មួយអើយយើងកើតមកជាអ្នកក្រមិនដែលញ៉ាំឆ្ងាញ់ទេកុំឆើតពេក។

ក៖ បាទ!

ខ៖
ហើយយើងមិនស្រួលញ៉ាំណាដូចគេអ្នកមានណាយើងអ្នកក្រមិចញ៉ាំដូចអ្នកមានបានយើងអ្នកក្រហើយយើងរកបានតិចហើយញ៉ាំតិចទៅហើយយើងរកបានច្រើនយើងបានញ៉ាំបានច្រើនទេហើយរកបានតិចញ៉ាំតិចទៅណា។

ក៖ បាទ!

ខ៖ ចាំ! រកបានច្រើនបានច្រើនទៅណា។

ក៖ បាទ!

ខ៖ ហើយនិងមធ្យមគ្រាន់តែអត់ជំពាក់គេនឹងណា។

ក៖ បាទ! ហើយអញ្ចឹងគ្រាន់អត់ជំពាក់គេណាម៉ាណោះ។

ខ៖ ចាំ! ហើយបើយើងនឹងញ៉ាំធំយើងនិងអត់ហើយ។

ក៖ បាទ! ហើយអញ្ចឹងម្ហូបដែរម៉ាចូលចិត្តជាងគេនិងគឺប្រហុកនឹងម៉ងម៉ា។

ខ៖ ចាំ! ខ្ញុំចូលចិត្តជាងគេនិងប្រហុកហើយនិងផ្អក់និងណា។

ក៖ បាទ! ហើយអញ្ចឹងម៉ាចូលចិត្តប្រហុកផ្អក់យើងនិងណាម៉ាណោះ។

ខ៖ ចាំ!

ក៖ បាទ! ហើយនិងម្ហូបដែរម៉ាចូលចិត្តជាងគេណាម៉ាណោះ។

ខ៖ ចាំ!

ក៖ បាទ!
ហើយអញ្ចឹងម៉ាបើនិយាយពីល្បែងប្រជាប្រិយភាពយើងនិងវិញណាម៉ាដូចជាល្បែងប្រជាប្រិយភាពដូច ចោលឈូង បោះអង្គញ ទាញ់ព្រ័ត្ត លាក់កន្សែង ហើយនិងល្បែងប្រជាប្រិយភាពអីផ្សេងនិងម៉ាមានចូលចិត្តទេម៉ា?

ខ៖ ចាំ! កាលពីដើមនិងខ្ញុំលេងដែរតើ!

ក៖ បាទ!ហើយអញ្ចឹងកាលនៅពីក្មេងម៉ាលេងដែរណាម៉ា។

ខ៖ ចាំ! ខ្ញុំធ្លាប់លេងដែរកាលដែរខ្ញុំនៅក្មេងៗនិងណា។

ក៖ បាទ! ហើយអញ្ចឹងម៉ាមានចូលចិត្តលេងអីជាងគេដែរម៉ា។

ខ៖ ចាំ!
បើនិយាយកាលពីចូលឆ្នាំនិងខ្ញុំចូលចិត្តលេងល្បែងប្រជាប្រិយភាពចោលឈូងនឹងណា។

ក៖ បាទ!ហើយអញ្ចឹងម៉ាចូលចិត្តលេងចោលឈូងម៉ាកាលម៉ានៅពីក្មេងណាម៉ាណោះ។

ខ៖ ចាំ!
ហើយនាំគ្នាលេងទៅណាហើយកាលពីជំនាន់ខ្ញុំនិងខ្ញុំលេងតើកាលនិងលេងសប្បាយណាស់គ្នាអ្នកណាគេមករករឿងអីទេ។

កៈ បាទ! ហើយអញ្ចឹងម៉ាកាលពីជំនាន់គេលេងច្រើនណាស់ម៉ាហើយគ្មានអ្នកណាគេមករករឿងទេណាម៉ាណោះ។

ខៈ ចាំ! គ្មានទេកាលនឹងនោះ?

កៈ បាទ!

ខៈ ចាំ! ហើយកាលជំនាន់ឥឡូវនិងគេអត់លេងទេ។

កៈ បាទ! ហើយអញ្ចឹងជំនាន់ឥឡូវនិងគេអត់លេងទេណាម៉ាណោះ។

ខៈ ចាំ! គេអត់លេងទេ។

កៈ បាទ!

ខៈ ហើយកាលពីជំនាន់ខ្ញុំនិងគេលេងច្រើនណាស់។

កៈ បាទ!

ខៈ ហើយកាលពីជំនាន់ខ្ញុំគេលេងពីរបីថ្ងៃនិងហើយគេឈប់។ហើយឥឡូវនិងគេអត់លេងផងនិង។

កៈ បាទ! ហើយអញ្ចឹងម៉ាបើនិយាយពីការរាំការច្រៀងនិងម៉ាមានចេះទេម៉ា?

ខៈ ចាំ! អត់ចេះទេរាំហើយនិងការច្រៀងនិងអត់ចេះទេខ្ញុំកាលនិងអត់ចូលចិត្តទេ។

កៈ បាទ!ហើយអញ្ចឹងកាលនិងម៉ាអត់ចេះរាំហើយនិងច្រៀងទេណាម៉ាណោះ។

ខៈ ចាំ!

កៈ បាទ!

ខៈ ហើយកាលនិងគេអត់រាំច្រៀងទេគេលេងតែអង្គុញនិងហើយនិងចោលឈូងនិងណាគ្មានទេ។

កៈ បាទ! ហើយអញ្ចឹងម៉ាចេះតែលេងបោះអង្គុញទេម៉ា?

ខៈ ចាំ! ខ្ញុំចេះតែលេងបោះអង្គុញនឹងណា។

កៈ បាទ! ហើយអញ្ចឹងកាលពេលចូលឆ្នាំខ្មែរនិងម៉ាមានទៅលេងនៅតាមភូមិហើយនិងតាមវត្តទេម៉ា?

ខៈ ខ្ញុំចូលចិត្តតើ។

កៈ បាទ! ហើយអញ្ចឹងមានតែឃើញកំលោះៗមកតាមញ៉ែម៉ាទេ?

ខៈ អត់ទេកាលនិងនោះ។

កៈ បាទ!ម៉ាគ្មានទេមានតែនាំគ្នាលេងទៅអញ្ចឹងម៉ា។

ខៈ ចាំ! អត់មានទេ។

កៈ បាទ!

ខៈ ចាំ! ហើយកាលនិងគេអត់ដែរមកញ៉ែអីទេគេលេងត្រង់ៗនិងទៅណា។

កៈ បាទ! ហើយអញ្ចឹងគេលេងត្រង់ៗអញ្ចឹងម៉ា។

ខៈ ចាំ!

កៈ បាទ! ហើយដូចគេសូមរាំជាមួយគ្នាអញ្ចឹងទៅណាម៉ា។

ខៈ អត់ទេកាលនិងនោះ។

កៈ បាទ! ហើយអញ្ចឹងអត់ដូចឥឡូវទេណាម៉ាណោះឲ្យតែឃើញជិះម៉ូតូតាមញ៉ែអញ្ចឹងណាម៉ា។

ខៈ ចាំ! នឹងហើយ។

កៈ បាទ! ហើយអញ្ចឹងម៉ាអត់ដែរស្គាល់កុងទេ។ហើយអញ្ចឹងម៉ាបើនិយាយពីក្រុមគ្រួសាររបស់ម៉ាហើយដូចជាបងប្អូនហើយចៅឬក៏បងប្អូនជីដូនមួយហើយនិងបងប្អូនអីមានអ្នកណាគេចេះលេងឧបករណ៍តន្រ្តីដូចជាលេងស្គរ រណាត ខ្លុយ ហ្គីតា ព្យាណូ ហើយនិងឧបករណ៍ផ្សេងទៀតមានទេម៉ា?

ខៈ ចាំ! នៅក្នុងក្រុមគ្រួសារនិងអត់មានគេចេះលេងទេឧបករណ៍តន្រ្តីអីទេ។

ក៖ បាទ! អត់មានទេ។ហើយអញ្ចឹងម៉ាបើនិយាយពីកាលពីផ្ទះរបស់ម៉ានឹងពេលដែរម៉ានៅជាមួយឪពុកម្តាយរបស់ម៉ាអញ្ចឹងណាមានលក្ខណៈផ្ទះស្បៅឬក៏ផ្ទះគ្បឿងម៉ា?

ខ៖ ចា៎! ហើយបើនិយាយពីផ្ទះរបស់ខ្ញុំនិងផ្ទះគ្បឿងនឹង។

ក៖ បាទ! ហើយអញ្ចឹងផ្ទះគ្បឿងនឹងម៉ា។

ខ៖ ចា៎! កាលនិងផ្ទះខ្ញុំនិងផ្ទះគ្បឿងតូចនិងហើយក្មួយខ្ញុំគេធ្វើថ្មីនិងទៅហើយគេរើសធ្វើថ្មីនឹងណា។

ក៖ បាទ! ហើយអញ្ចឹងដំបូងនិងដំបូងគ្បឿងហើយអញ្ចឹងជញ្ជាំងអីគេដែរម៉ា?

ខ៖ ជញ្ជាំងនិងជញ្ជាំងផ្ដុលនិង។

ក៖ បាទ!ហើយអញ្ចឹងរណាបអាស្សីនិងទៅ។

ខ៖ ចា៎! រណាបអាស្សីនិង។

ក៖ បាទ! ហើយអញ្ចឹងបើជើងសសរវិញម៉ា។

ខ៖ ជើងសសរឈើ។

ក៖ បាទ! ជើងសសរឈើ។

ខ៖ នោះអាឈើអញ្ចឹង។

ក៖ បាទ! ហើយអញ្ចឹងបើកាំជណ្តើរនិងឈើដែរម៉ា។

ខ៖ ចា៎! កាំជណ្តើរឈើនិងណាព្រោះអីក្មួយគេមានលុយធ្វើនិង។

ក៖ បាទ! ហើយអញ្ចឹងផ្ទះនឹងគាត់ធ្វើខ្លួនឯងឬក៏គាត់ជួលគេម៉ា។

ខ៖ ចា៎! គាត់អត់ជួលគេទេផ្ទះនិងតាំងពីតាខ្ញុំមកម្ល៉េះ។

ក៖ បាទ! ហើយអញ្ចឹងផ្ទះនិងតាំងពីតាយាយរបស់ម៉ាតែម្តងម៉ា។

ខ៖ ចា៎! តាំងពីតាយាយខ្ញុំនិងណា។

ក៖ បាទ!

ខ៖ គាត់ជាអ្នកធ្វើហើយបានចែកមកម្ដាយខ្ញុំ។

ក៖ បាទ! ហើយអញ្ចឹងម៉ាមានបានស្នងឬបន្តវេនពីឪពុកម្ដាយដូចជាកូរស្គរឆ្នោតហើយនិងដូចជាត្បាញផាមួងនិងត្បាញក្រមាហើយនិងចេះធ្វើកន្ទេលគប់ទេម៉ា?

ខ៖ ចាំ! អត់មានទេអត់ចេះទេអានឹងនោះគាត់រកតែធ្វើថ្នាំជក់និងណាហើយកាលនិងម៉ែរកអីកូនរកនិងដៃរនឹង។

ក៖ បាទ!ហើយអញ្ចឹងម្ដាយរបស់ម៉ាគាត់ប្រកបមុខរបរធ្វើថ្នាំជក់ហើយអញ្ចឹងម៉ាក៏ចេះរកតាមគាត់ទៅម៉ា។

ខ៖ ចាំ! ហើយសព្វថ្ងៃនិងគ្មានទេហើយរាល់ថ្ងៃនិងគេមានបងប្អូនគេនៅអាមេរិចទៅគេមានទៅណា។

ក៖ បាទ!

ខ៖ ហើយខ្ញុំអត់មានរកស៊ីទៅណាតាមកម្លាំងញឹសឈាមយើងទៅណាស់។

ក៖ បាទ!

ខ៖ ហើយបានបន្តិចញ៉ាំបន្តិចទៅហើយបានច្រើនញ៉ាំច្រើនទៅណាស់។

ក៖ បាទ!

ខ៖ រាល់ថ្ងៃនិងណា។

ក៖ បាទ!ហើយអញ្ចឹងរាល់ថ្ងៃនឹងបើនិយាយពីក្មេងរហូតដល់ធំនឹងម៉ាពេលដែរម៉ាបានចូលរៀនអញ្ចឹងម៉ាហើយម៉ាមានគោលបំណងហើយនិងមានក្ដីស្រមៃថាពេលដែរធំចង់ធ្វើជាគ្រូបង្រៀនហើយនិងធ្វើគ្រូពេទ្យទាហានហើយនិងប៉ូលិសអញ្ចឹងណាសមានទេម៉ា?

ខ៖ ហើយខ្ញុំចេះតែមានក្ដីស្រមៃហើយតែយើងនិងអត់បានចូលរៀនអញ្ចឹងណាស់មានក្ដីស្រមៃណា។

កៈ បាទ!ព្រោះអីយើងអត់បានចូលរៀនណាម៉ាណោះ។

ខៈ
នឹងហើយរាល់ថ្ងៃអ្នកដែរមិនចង់បានអញ្ចឹងនោះហើយអ្នកណាដែរមិនចង់មានបានអញ្ចឹង
ម៉ា។

កៈ បាទ! ហើយអញ្ចឹងបានត្រឹមតែធ្វើចំការហើយនិងធ្វើត្បាញនិងទៅណាម៉ា។

ខៈ ចាំ! ស្រុកនឹងមានធ្វើអីក្រៅពីចំការនិងត្បាញនិងណា។

កៈ បាទ!
ហើយអញ្ចឹងម៉ាមានពាក្យអីចង់ផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយរបស់ម៉ាអញ្ចឹងឲ្យគាត់ខិតខំ
ប្រឹងរៀនហើយនិងកុំឲ្យដូចម៉ាអញ្ចឹងណាស់ម៉ា?

ខៈ ចាំ! រាល់ថ្ងៃចេះតែថាហើយថាឲ្យខំប្រឹងរៀនទៅ។

កៈ បាទ!
ឲ្យគាត់ខំប្រឹងរៀនទៅហើយបានការងារល្អនិងប្រាក់ខែច្រើនដូចគេអញ្ចឹងណាម៉ា។

ខៈ ចាំ!
នឹងហើយឲ្យបានការងារល្អធ្វើហើយនិងមានលុយច្រើនទៅណាស់។ហើយខ្ញុំចេះតែនិយា
យអញ្ចឹងណាស់គេស្ដាប់ទៅហើយគេមិនស្ដាប់ក៏អត់ទៅណាស់។

កៈ បាទ! ហើយអត់ដឹងថាធ្វើមិចណាម៉ាណោះ។

ខៈ ចាំ!

កៈ បាទ!
ហើយអញ្ចឹងម៉ាបើនិយាយពីការឲ្យគាត់ជៀសវាងពីគ្រឿងញៀនហើយនិងល្បែងស៊ីសង
ហើយនិងបងតូចបងធំអញ្ចឹងម៉ា?

ខៈ ចាំ! នឹងហើយរាល់ថ្ងៃនិងខ្លាចនិងហើយនិងខ្លាចខ្លាំងណាស់រាល់ថ្ងៃនិងណាស់។

កៈ បាទ!

ខៈ
ហើយគ្រាន់តែរកស៊ីវាអត់អីទេវាល្អមើលហើយខ្លាចជាងគេនិងអាគ្រឿងញៀនម៉ងណា។

កៈ បាទ!

ខ៖ ហើយដើរពេលលែងនិងខ្លាចអានឹងណាស់។

ក៖ បាទ!

ខ៖ ហើយអានឹងខ្លាចខ្លាំងណាស់ណារាល់ថ្ងៃនិងខូចខ្មែរយើងអស់ច្រើនណាស់ណា។

ក៖ បាទ!

ខ៖ ហើយអានឹងមនុស្សល្អទៅមនុស្សអាក្រក់និងណាស់។

ក៖ បាទ! ហើយអញ្ចឹងម៉ាមានពាក្យអីជាចុងក្រោយទៀតអត់ម៉ា។

ខ៖ ចា៎! ខ្ញុំអត់មានពាក្យអីនិយាយទៀតទេ។

ក៖ បាទ! ហើយអញ្ចឹងជាចុងក្រោយម៉ាខ្ញុំសូមអរគុណម៉ាដែរបានអនុញ្ញាតឲ្យខ្ញុំធ្វើការសម្ភាសន៍ពីជីវប្រវត្តិរបស់ម៉ាមកកាន់សាលា BYU យើងខ្ញុំអញ្ចឹងម៉ា។ហើយអញ្ចឹងម៉ាអនុញ្ញាតឲ្យខ្ញុំយកសម្លេងរបស់ម៉ាទៅឲ្យសាកលវិទ្យាល័យ BYU នៅអាមេរិចបានទេម៉ា?

ខ៖ ចា៎! អត់អីទេហើយបើខ្ញុំនិយាយហើយមានមិចហើយកុំឲ្យមានរឿងដល់ខ្ញុំទៅបានហើយ។

ក៖ បាទ! ហើយអញ្ចឹងជាចុងក្រោយខ្ញុំសូមជូនពរឲ្យម៉ាមានសុខភាពល្អហើយមានកម្លាំងគ្រាប់គ្រាន់សម្រាប់ជាម្លប់ដល់កូនរបស់ម៉ាអញ្ចឹងម៉ា។ហើយសូមឲ្យកុងមានសុខភាពល្អផងដែរកុងហើយកូនចៅរបស់ម៉ាមានការរកស៊ីចេះតែមានអញ្ចឹងម៉ា។

ខ៖ ចា៎! អរគុណ។

ក៖ បាទ!ហើយអញ្ចឹងសូមជំរាប់លា។

ខ៖ ចា៎!